**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ

លេខ : ០១ ដនស/សរណេន

# សារាចរណែនាំ

## ស្តីពី

## ការអនុវត្តនីតិវិធីនៃការធ្វើសេចក្តីសម្រេចលើសំណុំរឿងវិវាទដីធ្លី របស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ក្នុងយន្តការគណៈកម្មការសុរិយោដី

អនុលោមតាមលិខិតលេខ ១៦៧៤សជណ.ឧស ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងប្រកាសលេខ ០៣២ប្រក.ដនស/គសជ. ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការធ្វើប្រតិភូកម្មមុខងារជូនដល់អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈកម្មការសុរិយោដីរាជធានី ខេត្ត ដើម្បីធ្វើសេចក្តីសម្រេចលើសំណុំរឿងវិវាទដីធ្លីក្នុងយន្តការរបស់គណៈកម្មការសុរិយោដី។ គណៈកម្មការសុរិយោដីថ្នាក់ជាតិសូមធ្វើការណែនាំអំពីការអនុវត្តនីតិវិធីនៃការធ្វើសេចក្តីសម្រេចដូចតទៅ :

១-បន្ទាប់ពីបានទទួលសំណុំរឿងវិវាទដីធ្លីដែលដោះស្រាយដោយការសម្រុះសម្រួលមិនបានជោគ-ជ័យនៅគណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ក៏ដូចជាសំណុំរឿងវិវាទដែលមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី និងសំណុំរឿងវិវាទបញ្ជូនពីគណៈកម្មការសុរិយោដីថ្នាក់ជាតិរួចមក គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវពិនិត្យសំណុំរឿងវិវាទទាំងមូលដើម្បីឱ្យច្បាស់ថា តើគណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ បានអនុវត្តត្រឹមត្រូវពេញលេញតាមនីតិវិធីហើយឬនៅ? ក្នុងករណីគណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ អនុវត្តពុំត្រឹមត្រូវតាមនីតិវិធីទេនោះ គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវបញ្ជូនសំណុំរឿងវិវាទទៅគណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ឱ្យអនុវត្តនីតិវិធីឡើងវិញ។

ចំពោះសំណុំរឿងវិវាទដែលស៊ើបអង្កេតមិនបានពេញលេញ គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវចាត់មន្ត្រីលេខាធិការដ្ឋានចុះស៊ើបអង្កេតបន្ថែមឱ្យបានពេញលេញ។

២-ចំពោះសំណុំរឿងវិវាទដែលបានអនុវត្តត្រឹមត្រូវតាមនីតិវិធីរួចហើយ គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវព្យាយាមអញ្ជើញភាគីវិវាទឱ្យចូលរួមធ្វើការសម្រុះសម្រួលយ៉ាងតិច ៣ (បី)លើក ឬអាចលើសពីនេះតាមការយល់ឃើញរបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ក្នុងគោលបំណងបញ្ចប់វិវាទជាឯកច្ឆ័ន្ទនៅក្នុងសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់រាជធានី ខេត្ត និងស្របតាមនីតិវិធីដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ៤៧អនក្រ.បក. ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ និង ប្រកាសលេខ ១១២ដនស.ប្រក. ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២។

៣-ប្រសិនបើភាគីវិវាទទាំងអស់ពុំព្រមព្រៀងគ្នាបញ្ចប់វិវាទជាឯកច្ឆ័ន្ទតាមការសម្រុះសម្រួលដូចបានចែងខាងលើទេនោះ គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវបើកកិច្ចប្រជុំដើម្បីធ្វើសេចក្តីសម្រេចចំពោះសំណុំរឿងវិវាទ ដោយផ្អែកលើលទ្ធផលនៃការស៊ើបអង្កេត និងសេចក្តីសន្និដ្ឋានរបស់លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ។

៤-សេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវធ្វើជាលាយល័ក្ខអក្សរ និងត្រូវមានសេចក្តីសង្ខេបអំពីករណីវិវាទ និងហេតុផលលំអិតនៃការធ្វើសេចក្តីសម្រេចទទួលស្គាល់ភោគីត្រឹមត្រូវតាមច្បាប់ (ឧបសម្ព័ន្ធទី២៣) ។ លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវធ្វើសេចក្តីប្រកាស និងប្រគល់សេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ជូនដល់ភាគីវិវាទ។

៥-ករណីភាគីវិវាទមិនសុខចិត្តចំពោះការសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ភាគីមានសិទ្ធិស្នើសុំឱ្យគណៈកម្មការសុរិយោដីថ្នាក់ជាតិ បើកសវនាការសម្រេចលើករណីវិវាទនោះឡើងវិញ ក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការដោយគិតចាប់ពីថ្ងៃដែលបានទទួលសេចក្តីសម្រេច ឬថ្ងៃដែលបានជូនដំណឹងអំពីសេចក្តីសម្រេចនោះ។ ភាគីដែលស្នើសុំឱ្យបើកសវនាការសម្រេចឡើងវិញត្រូវជូនដំណឹងជាលាយល័ក្ខអក្សរដាក់ទៅលេខាធិការគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលបានចេញសេចក្តីសម្រេចនោះ (ឧបសម្ព័ន្ធទី២៤) ។

៦-បន្ទាប់ពីបានទទួលសំណើសុំឱ្យបើកសវនាការសម្រេចឡើងវិញរួចហើយ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវរៀបចំបញ្ជូនសំណើ និងភ្ជាប់ជាមួយនូវសំណុំរឿងវិវាទទៅគណៈកម្មការ

សុរិយោដីថ្នាក់ជាតិ យ៉ាងយូរក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការដោយគិតចាប់ពីថ្ងៃទទួលបានសំណើនេះ។ ប្រសិនបើគ្មានការស្នើសុំឱ្យបើកសវនាការសម្រេចឡើងវិញក្នុងរយៈពេលកំណត់ខាងលើនេះ សេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវចាត់ទុកជាសេចក្តីសម្រេចស្ថាពរ។

៧-ទទួលបានសារាចរណែនាំនេះ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត មានភារកិច្ចចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ

អ៊ឹម ឈុនលឹម

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

- គណៈកម្មការសុរិយោដីរាជធានី ខេត្ត

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ